# ស្ថានទូតអូស្ត្រាលី
# រាជធានីភ្នំពេញ

# សេចក្តីប្រកាសព័ត៌មាន
## វីដេអូស្តីអំពីអនាគតគ្មានដែនកំណត់បង្ហាញពីការផ្សព្វផ្សាយអប់រំសកល

ថ្ងៃនេះ លោកជំទាវ **ផេននី រីឆាដស៍** (Penny Richards) ឯកអគ្គរាជទូតអូស្ត្រាលីប្រចាំប្រទេសកម្ពុជា បានចូលរួមសម្ពោធខ្សែវីដេអូមួយដែលផ្សព្វផ្សាយអំពីវិស័យសិក្សាអប់រំអន្តរជាតិរបស់អូស្ត្រាលីដែលមានឈ្មោះថ្មីថា *អនាគតគ្មានដែនកំណត់* ។

បង្កើតឡើងដោយភ្នាក់ងារផ្សាយពាណិជ្ជកម្មសាលក (M&C Saatchi) និងផលិតដោយក្រុមហ៊ុនដែលទទួលពានរង្វាន់ (Animal Logic) ដែលជាអ្នកផលិតខ្សែភាពយន្តល្បីៗជាច្រើនដូចជា (Happy Feet) ដែលជាវីដេអូប្រើបច្ចេកទេសចលនាដើម្បីបង្ហាញអំពីតំលៃការសិក្សាអប់រំរបស់អូស្ត្រាលីដែលជាការវិនិយោគមួយនៅថ្ងៃអនាគត ។

លោកជំទាវ **រីឆាដស៍** បានមានប្រសាសន៍ថា គោលបំណងនៃខ្សែភាពយន្តនេះគឺដើម្បីគូសបញ្ជាក់ថាប្រទេសអូស្ត្រាលីជាប្រទេសមួយដែលផ្តល់សេវាសិក្សាអប់រំប្រកបដោយគុណភាពខ្ពស់ ជាជាងជាទីកន្លែងដ៏ល្អមួយសំរាប់រស់នៅក្នុងពេលសិក្សា ។ ខ្សែវីដេអូនេះត្រូវបានបង្កើតឡើង ដោយអនុលោមតាមយុទ្ធនាការផ្សព្វផ្សាយរបស់រដ្ឋាភិបាលដែលមានឈ្មោះថា អូស្ត្រាលីគ្មានដែនកំណត់ ដែលសម្ពោធកាលពីឆ្នាំ២០១០ ។

ខ្សែវីដេអូដ៏ថ្មីស្រឡាងមួយនេះ គឺជាផ្នែកមួយនៃយុទ្ធសាស្រ្តបន្តបន្ទាប់របស់ប្រទេសអូស្ត្រាលីក្នុងការលើកស្ទួយវិស័យសិក្សាអប់រំអន្តរជាតិរបស់ខ្លួន ដែលបានទាក់ទាញនិស្សិតអន្តរជាតិជាង 554,000 នាក់ មកពីប្រមាណ២០០ប្រទេស ក្នុងឆ្នាំ២០១១។

លោកជំទាវ **រីឆាដស៍** បានមានប្រសាសន៍ថា រដ្ឋាភិបាលអូស្ត្រាលីបន្តការប្តេជ្ញាចិត្តដើម្បីធានាអោយបានថា វិស័យសិក្សាអប់រំរបស់ខ្លួនរក្សាបាននូវកិត្តស័ព្ទជាអន្តរជាតិថាជាវិស័យសិក្សាអប់រំដ៏ល្អបំផុត ។

No. 16B National Assembly Street, Sangkat Tonle Bassac, Khan Chamkamon, Phnom Penh, Kingdom of Cambodia
Telephone: 855 23 213 470 Facsimile: 855 23 213 413

លោកជំទាវ **រីឆាដស៍** បានមានប្រសាសន៍បន្ថែមថា ការសិក្សាអប់រំអន្តរជាតិលើកតម្កើងទំនាក់ទំនងពាណិជ្ជកម្ម និងសង្គម រវាងអូស្រ្តាលី និងដៃគូរពាណិជ្ជកម្មទាំងឡាយរបស់ខ្លួន ដែលនេះជាអង្គទូតអមតៈរបស់អូស្រ្តាលី ។

ស្ថាប័នរបស់យើងគឺស្ថិតក្នុងចំណោមស្ថាប័នដ៏ល្អបំផុតក្នុងពិភពលោក ដែលជួយអោយនិស្សិតទាំងឡាយទទួលបានចំណេះដឹង ជំនាញ បណ្តាញទំនាក់ទំនងគ្នា ដែលគង់វង្សអស់មួយជីវិត ។

លោកអ្នកអាចចូលមើលវីដេអូនេះបានតាមរយៈគេហទំព័រ www.studyinaustralia.gov.au ឬ www.australiaunlimited.com.au. លោកអ្នកដែលមានម៉ាស៊ីនថេបលេត ក៏អាចដូនឡូតកម្មវិធី Australia Unlimited បានផងដែរ ។ ការបោះពុម្ពផ្សាយក្នុងខែមីនា ២០១២ នេះ មានលក្ខណៈពិសេសដោយបានបង្ហាញអំពីខ្សែវីដេអូថ្មីដោយមានសំលេង ដែលមានឈ្មោះថាអនាគតគ្មានដែនកំណត់ ។

**សំរាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង៖**
លោក **ដេវ ហ្គរ័ដ្យ** ( Dave Gordge ) អនុប្រធានបេសកកម្ម
ស្ថានទូតអូស្រ្តាលី រាជធានីភ្នំពេញ ទូរស័ព្ទលេខ ០២៣២១៣ ៩៧០
ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១២